# ចំការចេក

## (Banana Orchards)



ប្រែសម្រួលដោយ លោក សុមសាក់ វ៉ាន់ណាសារី
បកប្រែថតចម្លងលើកទី 4

**By Somsak Wannasaree**
**Translation Copy No. 4**
**January 1997**

# ដំណាំចេក

| មាតិការឿង | ទំព័រ |
|---|---|
| 1. ប្រវត្តិរបស់ដំណាំចេក | 1 |
| 2. ភូតគ្រាមសាស្ត្ររបស់ចេក | 4 |
| 3. ពូជចេក | 11 |
| 4. ពូជចេកដែលដាំនៅស្រុកយើង | 15 |
| 5. ការលូតលាស | 17 |
| 6. ការពង្រីកពូជ (បំបែកពូជ) | 30 |
| 7. ការដាំនិងចន្លោះនៃការដាំ | 33 |
| 8. ការពូនគល់និងការកាត់តែងធាង | 35 |
| 9. ការដាក់ជីនិងផ្តល់ទឹក ឬស្រោចទឹក | 39 |
| 10. ការប្រមូលផល | 42 |
| 11. ការកាត់និងបន្ទំចេក | 45 |
| 12. ការវិចខ្ចប់ចេកដាក់ក្នុងវត្ថុសំរាប់ដឹកនាំ | 47 |
| 13. ចេកពងមាន់កំផែងពេជ្រ | 51 |
| 14. ជម្ងឺរបស់ចេក | 61 |
| 15. សត្វល្អិតដែលជាសត្រូវរបស់ចេក | 67 |

ម.ព.ឯ.ក AIDOC
Code: 176-002
Date:
Donated by:

អំណោយ
អ្នកឧកញ៉ា ចន្ទ_សារុន

# 1. ប្រវត្តិរបស់ដំណាំចេក

ចេកដែលមាននៅក្នុងបច្ចុប្បន្ននេះមានដើមកំណើតនៅភូមិភាគអាស៊ីអាគ្នេយ៍ ។ ពិតមែនតែចេកពុំបានដាំជាទូទៅនៅក្នុងសម័យនោះក៏ដោយ តែប្រជាពលរដ្ឋបានស្គាល់ថាចេកជាដំណាំហូបផ្លែដែលមនុស្សដាំដើម្បីជាអាហារបាន និងប្រើជាប្រយោជន៍ផ្សេងៗជាយូរយារណាស់មកហើយ ។ ស្លឹកចេកព្រៃយកមកខ្ចប់របស់ផ្សេងៗ ឬស្រ្យកដើមធ្វើខ្សែ ហើយផ្លែចេកយកមកទទួលទាន ។ ចេកជាពូជដែលកើតឡើងពីការក្លាយពូជមកពីចេកព្រៃដែលមានរស់ជាតិផ្អែម ជាហេតុនាំអោយមនុស្សយកចេកនោះមកដាំនៅបរិវេណជិតៗផ្ទះ ដើម្បីពុំចាំបាច់ទៅស្វែងរកនៅក្នុងព្រៃ ដូច្នេះទើបមានការជ្រើសរើស និងកែប្រែអោយបានពូជដែលល្អឡើងជាឡើយៗ ដោយការប្រើកូនចេកក្នុងការបន្តពូជតៗមក កាលពីដើមឡើយចេកព្រៃសម្បូរណ៍ទៅដោយគ្រាប់ឆ្លងតាមការជ្រើសរើសពូជ ទើបយើងទទួលបានចេកដែលគ្មានគ្រាប់ដូចសព្វថ្ងៃនេះ ។

ចំណែកការពង្រីកពូជចេកមានការអះអាងដល់ចេកក្នុងប្រទេសឥណ្ឌាតាំងពី 600 ឆ្នាំមុន គ.ស និងពោលដល់ការក្លាយពូជចេកកាលពី 2000 ឆ្នាំមកហើយ ក្នុងប្រទេសចិនចាប់មានពូជចេកកាលពី គ.ស 200 ចំណែកភូមិភាគ មេឌីទែរ៉ាណេមិនមានការដាំចេករហូតដល់ គ.ស 650 ក្រោយពីនោះមកទើបមានជនជាតិអារ៉ាប់បានធ្វើដំណើរជួញប្រែជាមួយអាហ្វ្រិក បាននាំពូជចេកចូលទៅអាហ្វ្រិក ។ តមកក្នុងសតវត្សទី 15 ជនជាតិអ៊ឺរ៉ុបបានមកពិនិត្យភូមិ-ភាគជនជាតិបារាំងនៅអាហ្វ្រិកខាងលិចប្រទះឃើញមានការដាំដុះចេកពាសពេញ ។ ក្នុង គ.ស 1400 ជនជាតិព័រទុយហ្គាល់បាននាំចេកទៅកោះខានារី ហើយចាប់តាំងពីពេលនោះមកចាប់ផ្ដើមនាំពូជចេកចូលទៅអឌ្ឍគោលខាងលិចនិងក្នុងដើមសតវត្សទី 16 មានការនាំពូជចេកទៅសានតាដូមិងកូ ពូជចេកដែលស្គាល់ជាទូទៅដំបូង ក្នុងអឌ្ឍគោលខាងលិចគឺ Silk Fig និង French Plantain ដែលជាមូលដ្ឋានក្នុងការបែងចែកពូជតទៅ ៖

នៅដើមសតវត្សទី 19 ពូជចេកបារាំង (អំបូងមាស) (Gros Michel) និងចេកពូជហាមខម ( Dwarf Cavendish ) បាននាំចូលមកក្រុមកោះខារិបៀន រួមទាំងពូជផ្សេងៗទៀតច្រើនពូជបាននាំចូលមកពីចំការ Kew មករួបរួមទុកឯ ដូមិនិកា កាលពី គ.ស 1902 ដែលជាតំបន់ក្តៅ ហើយមានការដាំចេកច្រើនពូជដើម្បីប្រើជាអាហារ ។ ភាគច្រើនដាំនៅតំបន់អេក្វាទ័រឡើងទៅខាងជើង និងចុះមកខាងត្បូងរីកដាលទៅក្នុងកន្លែងដែលមានសីតុណ្ហភាពដីនិងសំណើមសមស្រប ពូជចេកដែលសំខាន់ក្នុងទីផ្សារជំនួញរបស់ពិភពលោកសម័យនេះគឺពូជចេក ហាមថង (អំបូងមាស) (Gros Michel) សូម្បីតែមិនធន់ទ្រាំដល់ជម្ងឺងាប់ពាយ (Panama diseases) ក៏ដោយពូជនេះគេយល់ថានាំមកដាំដៅអង្គ្លេសខាងលិច ជាលើកដំបូងដោយអ្នកភូតព្រាលសាស្ត្រ ជនជាតិបារាំងគេនៅលោក Francois Pouat ក្នុង គ.ស 1836 ។ ចំណែកក្នុង ជំណាលចាស់របស់ស្ពេនពោលថាមានអ្នកជួបប្រទះពូជចេកមានម្សៅច្រើន ដែលជាទូទៅក្នុងនាមថា Plantain ក្នុងបរិវេណតំបន់ក្តៅរបស់អាមេរិកា កាលគ.ស 1504 ដល់គ.ស 1516 de Berlanga ដែលជាអ្នកបួស និងជាអ្នកពិនិត្យកោះ កាឡាប៉ាកសបាននាំចេកដែលមានជាតិស្ករមកពីក្រុមកោះខានារិ ទៅសានតាដូមិងកូ ហើយបានពង្រីកទៅតាមតំបន់ផ្សេងៗ ចំណែកនៅទ្វីបអាមេរិកខាងជើង និងអ៊ឺរ៉ុបខាងលិចចាប់ផ្តើមស្គាល់ចេកក្នុង គ.ស 1866 ។

បច្ចុប្បន្នចេកមានការដាំទូទៅក្នុងតំបន់អេក្វាទ័រឡើងទៅខាងជើង និងចុះមកខាងត្បូងក្នុងប្រទេសដែលមានអាកាសធាតុសមរម្យដល់ការដាំចេក និងមានផលិតផលរបស់ចេកដើម្បីបរិភោគក្នុងភូមិឋានមានទាំងប្រទេសក្នុងទ្វីបអាហ្វ្រិកកា អាស៊ីនិងក្រុមកោះក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ចេកមានដើមកំណើតនៅភូមិភាគអាស៊ីអាគ្នេយ៍ ដូចបានរៀបរាប់ខាងលើមកហើយខ្លាំងជាងនេះទៅទៀតនៅមានអ្នកពោលថាមានចេកច្រើនជាង 13 ពូជដែលមានដើមកំណើតនៅក្នុងប្រទេសថៃ ។

ចំពោះការដាំចេកក្នុងប្រទេសថៃចាប់ផ្តើមមានដាំច្រើនក្នុង ព.ស 2507 ក្រោយពីពេលរដ្ឋាភិបាលជប៉ុនបានបើកទីផ្សារ ចេកហាមថៃ ដែលមានពីរពូជគឺ ចេកហាមថង ចេកហាមខៀវ

និងចេកហាមខម ចេកហាមថងជាពូជដែលមានដាំច្រើន ចំណែកចេកហាមខៀវមានដាំក្នុងខេត្តភាគខាងត្បូង និងចេកហាមខមក៏មានដាំច្រើនក្នុងភាគខាងត្បូង ។ ដូចគ្នាតែមិនមានការសំខាន់ផ្នែកខាងសេដ្ឋកិច្ចច្រើនទេក្នុងខណៈនេះ ។ ក្រៅពីនេះនៅមានចេកដែលគួរចាប់អារម្មណ៍មួយពូជទៀតគឺពូជចេកហាមលឿងដែលបានជួបប្រទះក្នុងស្រុក ណោទ្ធិ និងស្រុកសាក់ដៅ ជាពូជដែលមានលក្ខណៈប្រហាក់ប្រហែលនិងពូជចេករបស់ ម៉ាឡាស៊ី លក្ខណៈរបស់ដើមវាធំជាងចេកហាមថង ហើយស្នូងធំជាងមាន 8-10 ផ្លែស្និតធំ កាលណាចាស់ផ្លែជ្រុង ចុងផ្លែមិនស្លៀបច្រើនដូចចេកហាមថង ផ្លែទុំពណ៌លឿងខ្ចី សំបកក្រាស់ សាច់ធូរក្រអូបបន្តិចបន្តួចទុកមិនបានយូរតមកផ្លែច្រើនជ្រុះ ។



# 2. ភូតគាមសាស្ត្ររបស់ចេក

ចេកជាឈើដុះពីគល់ក្តិលធំហើយមានអាយុច្រើនឆ្នាំក្នុងត្រកូល Musaceae កាលណាធំពេញទីអាចមានកំពស់ 2-9 ម៉ែត្រ ។ តួដើមពិតប្រាកដរបស់ចេកដុះពីក្តិលនៅក្នុងដីចំណែកដើមដែលមើលឃើញជាតួដើមក្លែងក្លាយប្រកបទៅដោយធាងស្លឹក ដែលត្រួតលើគ្នាណែនរាងដើមផ្នែកខាងលើមានស្លឹក និងទងផ្កាដែលកើតមកពីចំណុចដុះរបស់ក្តិលខាងផ្នែកលើដីមានកណ្តាប់បំពង់វុក្ខសពោរពេញទៅដោយទឹកជ័រ ។ នៅគ្រប់ផ្នែករបស់ដើមមានលក្ខណៈជាអាស៊ីដតិចៗហើយរស់ជាតិចត់ ។

រុក្ខជាតិក្នុងត្រកូលនេះ Musaceae ចែកចេញជាពីរតាមលក្ខណៈរបស់ការបែកគុម្ពគឺត្រកូលចេក (Ensete) បានដល់ចេញដែលមិនបែកគុម្ពឡើងជាដើមមួយៗមានអាយុប្រហែលពីរឆ្នាំឬច្រើនជាងផ្លែទទួលទានមិនបាន កាលណាមានគ្រាប់ហើយដើមក៏ងាប់ទៅវិញ ប្រើធ្វើម្សៅឬយកសសៃ ចំណែកត្រកូលមួយទៀតគឺត្រកូលចេកបែកគុម្ព (Musa) បានដល់ចេកដែលមានជាទូទៅនៅក្នុងពេលបច្ចុប្បន្នមានការបែកគុម្ពឬដុះផ្លែ កូនអាចយកមកបរិភោគបាន ឬធ្វើអាហារ ។

ឫស ក្នុងរយៈដំបូងនៃការលូតលាស់ ឬក្នុងរយៈកូនតូចមានឫសកែវ បន្ទាប់មកនិងប្តូរជាឫសជញ្ជាក់ដូចគ្នានិងឫសចេកដែលដុះចេញពីក្តិលដុះចាក់ចេញទៅគ្រប់ទិសជុំវិញក្តិល ដំបូងឫសមានពណ៌ស ហើយផ្លោសបន្ទាប់មកផ្លាស់ទៅជាពណ៌ត្នោតចាស់ វិជ្ជមាត្ររបស់ឫសប្រហែល 5 - 8 មីលីម៉ែត្រ ហើយប្រវែងប្រមាណ 20 - 39 សង្ទីម៉ែត្រ ឫសដុះជាក្រុមៗមួយក្រុមមានប្រមាណ 4 ឫស នៅបរិមាណគល់ដើមក្នុងដី ដើមចេកដែលល្អអាចមានចំនួនឫសទៅដល់ 400 ឫសក្នុងមួយដើម ឫសដណ្តើមគ្នាភ្ជាប់ជារាងសំណាញ់ទៅតាមបរិវេណសើររាក់ៗ ហើយជ្រៅចុះទៅក្នុងដីប្រមាណ 15 សង្ទីម៉ែត្រ ក្នុងពេលខ្លះអាចប្រទះឃើញថាមានឫសនៅក្នុងលំដាប់ជ្រៅទៅដល់ 75 សង្ទីម៉ែត្រក៏មាន គឺឫសដែលដុះចេញពីក្តិល